ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍

## កិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសស្រលាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍

## ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

### ១-គោលបំណង

គោលបំណងនៃកិច្ចប្រជុំគឺ ពិនិត្យពិភាក្សាលើរបាយការណ៍នៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រលាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ និងការងារបច្ចេកទេសផ្តល់សេវាសុខភាពដល់ក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់។

តាមរយៈនៃកិច្ចប្រជុំ សមាជិកក្រុមការងារទាំងអស់រំពឹងថា នឹងបានឯកភាពគ្នាលើរបាយការណ៍នៃក្រុមការងារបច្ចេកទេសបុរសស្រលាញ់បុរសនិងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ និងផ្តល់ជាអនុសាសន៍ការងារបច្ចេកទេសនៃការផ្តល់សេវាសុខភាព។

### ២-កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន

កាលបរិច្ឆេទ: ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦

ទីកន្លែង : នៅសាលប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

វត្តមាន : អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍, MHC, MHSS,SIT,RHAC,CSSD, FHI360, CPN+,KHAMARA,UNAIDS and MEC។

### ៣-វិធីសាស្ត្រ : ពិភាក្សារួម

### ៤-លទ្ធផល

នៅថ្ងៃសុក្រ ទី០៨ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោង៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំនូវកិច្ចប្រជុំប្រចាំខែរបស់ក្រុមការងារលេខាធិការដ្ឋានបុរសស្រលាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានសមាជិកចូលរួមប្រមាណ១៣នាក់ ក្រោមការដឹកនាំកិច្ចប្រជុំដោយ ឯកឧត្តមវេជ្ជ. តែង គន្ធី អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។ ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រធានអង្គប្រជុំ បានថ្លែងអំណរគុណដល់សមាជិកក្រុមការងារលេខាធិការដ្ឋាន ដែលបានចូលរួមប្រជុំនាពេលនេះ ព្រមទាំងបានពិនិត្យពិភាក្សាលំអិតលើរបៀបវារៈដែលបានគ្រោងទុក ដោយសម្រេចលទ្ធផលដូចខាងក្រោម៖

១.របាយការណ៍នៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រលាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ បានពិនិត្យពិភាក្សាលំអិតទៅតាមជំពូកនីមួយៗដោយពិនិត្យលើអក្ខរាវិរុទ្ធ អត្ថន័យ និងខ្លឹមសារទាំងមូល។ ជាមួយគ្នានោះដែរ យើងក៏បានពិនិត្យផងដែរ នូវការដាក់បញ្ចូលរូបភាពដោយផ្សារភ្ជាប់ជាមួយអត្ថន័យខាងក្រោម។ នៅក្នុងរបាយការណ៍នោះ ក៏បានបង្ហាញពីការចូលរួមរបស់ក្រុមការងារ និងការសម្របសម្រួលសហការរវាងអាជ្ញាធរមូលដ្ឋាន នគរបាល គ្រូសារ និងដៃគូសហគមន៍ដើម្បីកាត់បន្ថយការមាក់ងាយ និងរើសអើង ក្នុងចំណោមក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់។ យើងក៏បានរំលេចផងដែរនូវឯកសារយោងរាល់ព័ត៌មានដែលទាក់ទងជាមួយទិន្នន័យ។

២.ការពិភាក្សាពីបច្ចេកទេសនៃការផ្តល់សេវាសុខភាពដល់ក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ មិនបានធ្វើការពិភាក្សាលំអិតទេ ដោយខាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ មិនបានចូលរួមក្នុងកិច្ចប្រជុំនេះទេ។

**៥-សំណូមពរ និងអនុសាសន៍**

ស្នើលេខាធិការដ្ឋានពង្រឹងនូវសមាជិកភាព និងការងារបច្ចេកទេសឲ្យកាន់តែប្រសើរជាងមុន។

**៦-ការងារដែលត្រូវធ្វើបន្ត**

១.ក្រុមការងារលេខាធិការដ្ឋាននឹងរៀបចំរបាយការណ៍នៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រលាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍២០១៥ ឲ្យកាន់តែល្អ។

២.រៀបចំកិច្ចប្រជុំប្រចាំខែនៃក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ នៅខែក្រោយ។/.

ភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦

| បានឃើញ និងឯកភាព | បានឃើញ និងពិនិត្យត្រឹមត្រូវ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| អគ្គលេខាធិការ | ប្រធាននាយកដ្ឋាន | |